

World Vision

កម្ពុជា

# របាយការណ៍ អភិវឌ្ឍន៍ប្រចាំឆ្នាំ ២០០៤

# ទស្សនៈវិស័យរបស់យើង

គឺចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូរណ៍

# សេចក្តីអធិស្ឋានរបស់យើង

សូមអោយទឹកចិត្តមនុស្សគ្រប់រូបមានឆន្ទៈដើម្បីសំរេចបំណងនេះ ។

# ពីនាយកប្រចាំប្រទេស

នៅឆ្នាំ ២០០៤ នេះ អង្គការទស្សនៈពិភពលោកកម្ពុជា បានបញ្ចប់វដ្តរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ជាមួយនឹងឱកាសការឆ្លុះបញ្ចាំងការរៀនសូត្រ និងការអបអរ ។ វិសាលភាព និងគុណភាពការងាររបស់អង្គការទស្សនៈពិភពលោកកម្ពុជា បានផ្លាស់ប្តូរយ៉ាងច្រើន ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ។ របាយការណ៍ប្រចាំឆ្នាំ ២០០៤ នេះ ផ្តល់នូវសេចក្តីសង្ខេបអំពីព័ន្ធកិច្ចដែលមានលក្ខណៈចំរុះរបស់អង្គការទស្សនៈពិភពលោកកម្ពុជាបច្ចុប្បន្ននេះ ។

ខណៈពេលដែលអង្គការទស្សនៈពិភពលោកឈានចូលយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំថ្មី យើងនឹងពង្រឹងការផ្តោតយកចិត្តទុកដាក់របស់យើង ទៅលើកុមារងាយរងគ្រោះ ដោយជាចំបងតាមរយៈកម្មវិធីអភិវឌ្ឍន៍សហគមន៍ប្រកបដោយនិរន្តរភាព និងផ្តោតទៅលើកុមារ ។ ការការពារកុមារ និងការចូលរួមរបស់កុមារគឺមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះវិធីដែលយើងបញ្ចូលដំណើរការអភិវឌ្ឍន៍សហគមន៍ទៅក្នុងការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្តូរ ។ ក្នុងគំរូនេះ យើងនឹងផ្តោតជំនាញតាមផ្នែករបស់យើងទៅលើវិស័យអប់រំសុខាភិបាល សន្តិសុខស្បៀង មេរោគអេដស៍/ជំងឺអេដស៍ និង សន្តិភាពនិងយុត្តិធម៌ ។

ឥទ្ធិពលរបស់យើង ក្នុងការផ្លាស់ប្រែជីវិតរស់នៅរបស់កុមារងាយរងគ្រោះ ត្រូវផ្អែកជាសំខាន់លើគុណភាពបុគ្គលិកអង្គការទស្សនៈពិភពលោកព្រមជាមួយនឹងភាពជាដៃគូជាមួយកុមារ សហគមន៍ រាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិ អង្គការអន្តរជាតិ និងម្ចាស់អំណោយរបស់យើង ។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអស់លោក លោកស្រី ទាំងអស់ដែលបានរួមចំណែកដោយពេញដោយពិភាក្សា ផ្តល់កំលាំងពលកម្ម ណែនាំ និងគាំទ្រដល់ព័ន្ធកិច្ចនេះ ។ គុណភាពនិងការប្តេជ្ញារបស់បុគ្គលិកអង្គការទស្សនៈពិភពលោក និងដៃគូទាំងឡាយរបស់យើង គឺជាប្រភពដ៏រឹងមាំនៃសេចក្តីសង្ឃឹមសំរាប់កុមារកម្ពុជា ។

ដោយក្តីគោរពរាប់អាន

Talmage Payne

**ថាល់ម៉េជ្យ ផេន**
នាយកប្រចាំប្រទេស



# ជំនួយស្បៀងអាហារសំរាប់អ្នកផ្ទុកមេរោគ អេដស៍/អ្នកជំងឺអេដស៍ និងកុមារកំព្រា និងកុមារងាយរងគ្រោះ

## ខែ តុលា ឆ្នាំ ២០០៣ :

អង្គការទស្សនៈពិភពលោកកម្ពុជា និងកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ បានចាប់អនុវត្តគំរោងរួមគ្នាមួយ ដែលផ្តោតទៅលើសុខភាព និងតំរូវការអាហារូបត្ថម្ភរបស់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ (PLHAs) ដោយក្នុងនោះរួមបញ្ចូលទាំងកុមារកំព្រា និងកុមារងាយរងគ្រោះ (OVCs) ផងដែរ ។ ការចែកស្បៀងជាអង្ករ ប្រេងឆា ដែលមានវីតាមីនអា និងអំបិលអ៊ីយ៉ូដប្រចាំខែ ធ្វើឡើងចំពោះអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងក្រុមគ្រួសារកុមារកំព្រា និងកុមារងាយរងគ្រោះនៅតាមសហគមន៍ជនបទ ។ ការចែកស្បៀងនេះ ធ្វើឡើងដើម្បីសំរួលដល់តំរូវការអាហារប្រចាំថ្ងៃរបស់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងសមាជិកគ្រួសារកុមារកំព្រា និងកុមារងាយរងគ្រោះ និងដើម្បីកាត់បន្ថយចំណាយមួយផ្នែកដោយផ្ទាល់ និងប្រយោល ដែលជាបន្ទុកកាន់តែធ្ងន់ឡើង ដោយសារការបាត់បង់ប្រាក់ចំណូល និងការចំណាយទៅលើថ្នាំព្យាបាលរបស់គ្រួសារអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងកុមារកំព្រា និងកុមារងាយរងគ្រោះ ។ គិតមកដល់ដំណាច់ខែ កញ្ញា ឆ្នាំ ២00៤ មានគ្រួសាររងគ្រោះដោយសារមេរោគអេដស៍ចំនួន ១៤៨២ គ្រួសារ នៅតាមកម្មវិធីអភិវឌ្ឍន៍តំបន់ (ADPs) ចំនួន ១៤ នៅខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តកំពង់ធំ បានទទួលផលពីគំរោងនេះ ។ ជំនួយស្បៀងអាហាររបស់កម្មវិធីស្បៀងអាហារពិភពលោកនេះ បានរួមវិភាគទានដល់វិធីសាស្រ្តចំរុះ និងគ្រប់ជ្រុងជ្រោយ ចំពោះការថែទាំតាមផ្ទះ ដែលបច្ចុប្បន្ននេះ កំពុងផ្តល់សេវាដល់ប្រជាជនចំនួន ២000 គ្រួសារ ។

*www.worldvision.org/hope*

# ស្វែងយល់អំពី
## សមត្ថភាពមូលដ្ឋានសំរាប់សន្តិភាព

### ខែ វិច្ឆិកា ឆ្នាំ ២០០៣ :

អង្គការទស្សនៈពិភពលោកកម្ពុជា បានបញ្ចប់សិក្ខាសាលាស្តីអំពីសមត្ថភាពថ្នាក់មូលដ្ឋានសំរាប់សន្តិភាព (LCP) រឺសិក្ខាសាលាស្តីអំពីការអនុវត្តន៍មិនអោយមានគ្រោះថ្នាក់ (Do No Harm) លើកដំបូងរបស់ខ្លួន ។ សមត្ថភាពថ្នាក់មូលដ្ឋានសំរាប់សន្តិភាពជួយបុគ្គលិកក្នុងការវិភាគទំនាស់ និងភាពតានតឹងនៅតាមសហគមន៍ ព្រមទាំងស្វែងយល់អំពីផលប៉ះពាល់នៃសកម្មភាពជំនួយសង្គ្រោះបន្ទាន់ និងសកម្មភាពអភិវឌ្ឍន៍ទៅលើទំនាស់ទាំងនោះ ។ អង្គការទស្សនៈពិភពលោកកម្ពុជា ប្តេជ្ញាបញ្ជ្រាបសមត្ថភាពថ្នាក់មូលដ្ឋានសំរាប់សន្តិភាពទៅក្នុងកម្មវិធីដោយទទួលស្គាល់ថា កម្មវិធីជំនួយសង្គ្រោះបន្ទាន់ និងកម្មវិធីអភិវឌ្ឍន៍អាចបង្កឱ្យមានគ្រោះថ្នាក់ និងបង្កើនឱ្យមានទំនាស់នៅតាមមូលដ្ឋានផង ឬក៏អាចបង្កើនសមត្ថភាពសហគមន៍អោយចេះរួមរស់ជាមួយគ្នាប្រកបដោយសន្តិភាពផងដែរ ។ សមត្ថភាពថ្នាក់មូលដ្ឋានសំរាប់សន្តិភាព ជួយដល់បុគ្គលិកក្នុងការវិភាគកម្មវិធីយ៉ាងប្រយ័ត្នប្រយែង ដោយពិនិត្យមើលពីរបៀបដែលបុគ្គលិកធ្វើអន្តរកម្មជាមួយទំនាស់ ឬភាពតានតឹងនៅតាមមូលដ្ឋាន បន្ទាប់មករៀបចំកម្មវិធីសាជាថ្មី ដើម្បីអោយផលប៉ះពាល់សង្គមរបស់ខ្លួនបានកាន់តែប្រសើរ ។ វគ្គបណ្តុះបណ្តាលសមត្ថភាពថ្នាក់មូលដ្ឋានសំរាប់សន្តិភាព មានទំនាក់ទំនងទៅនឹងគំរោងទាំងអស់របស់អង្គការទស្សនៈពិភពលោកកម្ពុជា ហើយជាមធ្យោបាយរៀបចំផែនការដ៏សំខាន់ ដើម្បីសំរេចគំរោងការអភិវឌ្ឍន៍ដែលនាំអោយមានការផ្លាស់ប្រែរបស់អង្គការទស្សនៈពិភពលោកកម្ពុជា ។ អង្គការទស្សនៈពិភពលោកកម្ពុជា ទទួលស្គាល់ភាពជាដៃគូ គឺជាមធ្យោបាយដ៏សំខាន់ក្នុងការកសាងសន្តិភាពក្នុងប្រទេសកម្ពុជា ។ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយក្រុមការងារដោះស្រាយទំនាស់ អង្គការធាបា្រន់ អង្គការសាសនា និងអង្គការដទៃទៀត អង្គការទស្សនៈពិភពលោករួមចំនែកក្នុងកិច្ចផ្តួចផ្តើមបញ្ឈប់អំពើហិង្សាប្រឆាំងនឹងកុមារ និងថែរក្សាជាតិពន្ធុនិយម ។

*www.justice-and-peace.org*





# ការចែកចាយវប្បធម៌ខ្មែរ

## ខែ ធ្នូ ឆ្នាំ ២០០៣ :

កុមារកម្ពុជាជាង ៣៣ ០០០ នាក់ បានសរសេរប័ណ្ណជូនពរបុណ្យអុំទូក ទៅដល់អ្នកទំនុកបំរុងអង្គការទស្សនៈពិភពលោករបស់ខ្លួន ។ ពិធីបុណ្យអុំទូកដែលប្រជាជនខ្មែរប្រារព្ធធ្វើប្រចាំឆ្នាំនៅ ខែ វិច្ឆិកា គឺជាថ្ងៃឈប់សំរាកដ៏ធំ និងសប្បាយរីករាយបំផុត ។ ក្រោយពីពិធីប្រណាំងទូក និងពិធីបុណ្យចប់ ទៅកុមារទំនុកបំរុងបានចែករំលែកបទពិសោធន៏របស់ខ្លួនពីព្រឹត្តិការណ៏ដ៏ពិសេសនេះដល់អ្នកទំនុកបំរុង តាមរយៈរូបគំនូរ និងសំណេរ ។

ក្នុងនាមជាអ្នកទំនុកបំរុងកុមារ អ្នកទំនុកបំរុងម្នាក់ៗនៅប្រទេសអូស្ត្រាលី កាណាដា ហុងកុង ម៉ាឡេស៊ី ជប៉ុន ណូវែលសឺឡង់ សឹង្ហបុរី ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក បានវិនិយោគទៅលើអនាគតរបស់កុមារកម្ពុជា ក្រុមគ្រួសារ និងសហគមន៏របស់កុមារទាំងនោះ ។ បច្ចុប្បន្ននេះ មានកុមារទំនុកបំរុងចំនួន ៤៥ ០០០ នាក់ នៅកម្ពុជា ។

www.wvi.org

# ការវាស់វែងសន្ទស្សន៍
## នៃការអភិវឌ្ឍន៍ដែលនាំអោយមានការផ្លាស់ប្រែ

### ខែ មករា ឆ្នាំ ២០០៤ :

កម្មវិធីអភិវឌ្ឍន៍តំបន់ បាទី បានបន្តវាស់វែងសន្ទស្សន៍នៃការអភិវឌ្ឍន៍ដែលនាំអោយមានការផ្លាស់ប្រែ នៅក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួន ។ " គោលបំណងនៃការវាស់វែងការអភិវឌ្ឍន៍ដែលនាំអោយមានការផ្លាស់ប្រែនេះ គឺដើម្បីបង្ហាញពីស្ថានភាព គុណភាពនៃជីវភាពរស់នៅរបស់សហគមន៍ គ្រួសារ និងកុមារ ដែលអង្គការទស្សនៈពិភពលោកកំពុងសំរបសំរួលកម្មវិធីអភិវឌ្ឍន៍ប្រកបដោយការផ្លាស់ប្រែ និងនិរន្តរភាពនៅតាមសហគមន៍ " ។

កម្មវិធីអភិវឌ្ឍន៍តំបន់ បាទី បានធ្វើអង្កេតលើគ្រួសារចំនួន ៩០០ ទាក់ទងនឹងការចាក់ថ្នាំបង្ការ អាហារូបត្ថម្ភ ការអប់រំ ទឹក ការគ្រប់គ្រងជម្ងឺរាគរូស ការស្តារស្ថានភាពរបស់គ្រួសារឡើងវិញ និងចំណេះដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ ។ យើងបានប្រើប្រាស់ក្រុមពិភាក្សា ដើម្បីវាយតំលៃសន្ទស្សន៍តាមបែបគុណភាព រួមមាន និរន្តរភាពសង្គម ការយកចិត្តទុកដាក់ចំពោះអ្នកដទៃ ព្រមទាំងការបំផុសសេចក្តីសង្ឃឹម ការចូលរួមរបស់សហគមន៍ និងគ្រួសារដែលក្រីក្របំផុត ។ នៅទូទាំងពិភពលោកទាំងមូល អង្គការទស្សនៈពិភពលោក ប្រើប្រាស់សន្ទស្សន៍បទដ្ឋានមួយឈុត ដើម្បីវាស់វែងការអភិវឌ្ឍន៍ដែលនាំអោយមានការផ្លាស់ប្រែនៅក្នុងសហគមន៍នីមួយៗ ដែលអង្គការធ្វើការយ៉ាងហោចរៀងរាល់ ៤ ឆ្នាំម្តង ។

*សៀវភៅណែនាំអំពីសន្ទស្សន៍អភិវឌ្ឍន៍ ដែលនាំអោយមានការផ្លាស់ប្រែ វ៉ុល ១ ដោយក្រុមធនធានអភិវឌ្ឍន៍នៃអង្គការទស្សនៈពិភពលោក ទំព័រ ២ ខែធ្នូ ឆ្នាំ ២០០២ ។*

www.transformational-development.org





# ការកាត់បន្ថយ

## ហានិភ័យនៅតាមលំនៅដ្ឋានអនាធិបតេយ្យ

### ខែ កុម្ភៈ ឆ្នាំ ២០០៤ :

អង្គការទស្សនៈពិភពលោកកម្ពុជា បានចូលរួមជាមួយសាលាក្រុងភ្នំពេញ UN-HABITAT អង្គការជនពិការអន្តរជាតិ ព្រះបរមរាជវាំង និងអង្គការផ្សេងៗទៀត ដើម្បីសំរបសំរួលការចែកចាយជំនួយសង្គ្រោះបន្ទាន់ដល់ក្រុមគ្រួសាររងគ្រោះ បន្ទាប់ពីមានសោកនាដកម្មអគ្គីភ័យមួយនៅតំបន់លំនៅដ្ឋានអនាធិបតេយ្យនៅទីក្រុងភ្នំពេញ ។

អង្គការទស្សនៈពិភពលោកកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលស្តីអំពីការត្រៀមបង្ការអគ្គីភ័យដល់ប្រជាជនចំនួន ៤០ គ្រួសារ ។ អ្នកភូមិនៅក្បែរ និងជនរងគ្រោះដែលរួចជីវិតពីអគ្គីភ័យដ៏អន្តរាយដែលបានសំលាប់កុមារា ២ នាក់ និងបំផ្លាញផ្ទះ ៩៦ ខ្នង នៅឆ្នាំ ២០០៣ បានចូលរួមក្នុងវគ្គនេះ ។ អង្គការទស្សនៈពិភពលោកកម្ពុជា បានឆ្លើយតបចំពោះការបំផ្លាញនៃអគ្គីភ័យនោះ ដោយផ្តល់ជាមូលនិធិសំរាប់សាងសង់ឡើងវិញនូវជំរកដែលមានលក្ខណៈអចិន្ត្រៃយ៍ជាងមុន ដោយផ្តល់ជាការបណ្តុះបណ្តាល និងផ្តល់ឧបករណ៍ពន្លត់អគ្គីភ័យដល់ក្រុមគ្រួសារទាំងនោះ ។ ក្នុងកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយហានិភ័យក្នុងចំណោមជនក្រីក្របំផុត វគ្គបណ្តុះបណ្តាលនោះមានគោលបំណងផ្តល់នូវការយល់ដឹងកាន់តែទូលំទូលាយអំពីហានិភ័យនៃអគ្គីភ័យ និងការបណ្តុះបណ្តាលសមាជិកសហគមន៍អំពីវិធីសាស្ត្រពន្លត់អគ្គីភ័យ ។

*www.reliefstandard.org*

*www.wvtsunami.org*

# អោយតំលៃការងារស្ត្រី

## ខែ មីនា ឆ្នាំ ២០០៤ :

ស្ត្រីមានដៃ ១០០ - ចូរអោយតំលៃការងារស្ត្រី ។ នេះជាការអំពាវនាវជាសាធារណៈដែលធ្វើឡើងដោយអង្គការទស្សនៈពិភពលោកកម្ពុជា ក្នុងយុទ្ធនាការមួយដែលធ្វើឡើងក្នុងទិវានារីអន្តរជាតិ ។

កញ្ញា ទេព ចាន់បូរ៉ា អ្នកសំរបសំរួលផ្នែកយេនឌ័រ និងការអភិវឌ្ឍន៏នៃអង្គការទស្សនៈពិភពលោកកម្ពុជា បានថ្លែងថា :

*" ស្ត្រីកម្ពុជាមានតួនាទីជាច្រើន និងយ៉ាងសំខាន់ដូចជា ការងាររកប្រាក់ចំណូល ការថែទាំ ការបោសសំអាត ការចំអិនអាហារ ការងារសហគមន៏ និងថែទាំកូនជាដើម ។ យើងចង់អបអរវិភាគទានដ៏មានតំលៃនេះ ដោយជាមួយគ្នានេះផងដែរ ទទួលស្គាល់នូវសិទ្ធិចូលរួមយ៉ាងពេញលេញរបស់ស្ត្រីនៅក្នុងសង្គម ដែលមិនផ្តល់បន្ទុកធ្ងន់ធ្ងរពេកទៅដល់ពួកគេ ។ យើងចង់អោយស្ត្រីមានមោទនភាពចំពោះវិភាគទានរបស់គេ នៅក្នុងការអភិវឌ្ឍន៏ប្រទេសកម្ពុជា ។ តាមរយៈកិច្ចប្រឹងប្រែងរបស់ខ្លួននៅតាមគ្រួសារ និងសហគមន៏ ស្ត្រីម្នាក់ៗ បានប្រើដៃ ១០០ ដើម្បីកសាងប្រទេសជាតិរបស់ខ្លួន " ។*

អង្គការទស្សនៈពិភពលោកកម្ពុជា ជាដៃគូការងារជាមួយអង្គការបណ្តាញការងារយេនឌ័រ និងអភិវឌ្ឍន៏បណ្តាញបុរសកម្ពុជា និងគណៈកម្មាធិការស្ត្រីកម្ពុជា ក្នុងការតស៊ូមតិអំពីច្បាប់ស្តីអំពីអំពើហិង្សាក្នុងគ្រួសារ និងសមធម៌យេនឌ័រ ព្រមទាំងដឹកនាំយុទ្ធនាការបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ ។

www.globalempowerment.org





# ការសម្ពោធអនុវិទ្យាល័យ

## ខែ មេសា ឆ្នាំ ២០០៤ :

អនុវិទ្យាល័យ សាមគ្គីមានជ័យ ដែលស្ថិតនៅក្នុងតំបន់ប្រតិបត្តិការសាមគ្គីមានជ័យ របស់អង្គការទស្សនៈពិភពលោកកម្ពុជា បានប្រារព្ធពិធីសម្ពោធអនុវិទ្យាល័យថ្មីរបស់ខ្លួន ។ សាលានេះបានស្ថិតនៅក្នុងស្ថានភាពទ្រុឌទ្រោមខ្លាំង មុនពេលអង្គការទស្សនៈពិភពលោកកម្ពុជា កសាងសំណង់នោះឡើងវិញ ។ ដើមឡើយថ្នាក់រៀនសង់ឡើងពីឫស្សី និងជញ្ជាំងស្លឹកដូង ។ សិស្ស និងគ្រូ គ្មានកន្លែងអង្គុយគ្រប់គ្រាន់ទេ ។ សាលានេះគ្មានទាំងបង្គន់ គ្មានទាំងទឹក ។

ឥឡូវនេះ អនុវិទ្យាល័យ សាមគ្គីមានជ័យ មានអគារសិក្សាថ្មីចំនួនបីខ្នង ធ្វើអំពីបេតុង និងឥដ្ឋ មានបង្គន់អនាម័យពីរ និងអគារការិយាល័យមួយខ្នង ។ មានអណ្តូងស្នប់មួយត្រូវបានសង់ឡើង ហើយសិស្ស និងគ្រូប្រើប្រាស់ទឹកពីអណ្តូងនោះស្រោចបន្លែ និងផ្កា ។ អគារសិក្សាថ្មីទាំងនេះ ក៏ផ្តល់លទ្ធភាពឱ្យសិស្សពិការចូលរៀនផងដែរ ។ គេរំពឹងថា នៅឆ្នាំសិក្សាក្រោយនេះ នឹងមានចំនួនកុមារចូលរៀនសាលានេះ កើនឡើងដល់ទៅ ១ ២00 នាក់ ។

www.child-rights.org

# វីសិនហ្វាន់កម្ពុជា

## បានទទួលអាជ្ញាប័ណ្ណ ជាស្ថាប័នមីក្រូហិរញ្ញវត្ថុ

### ខែ ឧសភា ឆ្នាំ ២០០៤ :

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់វីសិនហ្វាន់កម្ពុជា (VFC) ជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ វីសិនហ្វាន់កម្ពុជា គឺជាស្ថាប័នមីក្រូហិរញ្ញវត្ថុដាច់ដោយឡែកមួយ ដែលកាន់កាប់ និងគ្រប់គ្រងដោយ អង្គការទស្សនៈពិភពលោកកម្ពុជា ដែលផ្តល់កម្ចីខ្នាតតូចដល់សហគ្រិនក្រីក្រ ។ ស្ថាប័ននេះមានដំណើរការតាំងពីដើមឆ្នាំ ២០០១ មកម្ល៉េះ ហើយជាអ្នកផ្តល់ហិរញ្ញវត្ថុខ្នាតតូចភាគច្រើននៅជនបទ ប៉ុន្តែកំពុងចាប់ផ្តើមផ្តល់ហិរញ្ញវត្ថុខ្នាតតូចដល់ជនក្រីក្រទីក្រុង ដែលរស់នៅ និងធ្វើការនៅជុំវិញទីក្រុងភ្នំពេញហើយ ។

វិធីសាស្ត្ររបស់ វីសិនហ្វាន់កម្ពុជា គឺផ្តោតជាសំខាន់ទៅលើសហគ្រិនក្រីក្របំផុត ហើយជានិច្ចជាកាល រៀបចំឡើងជាផ្នែកចំរុះមួយនៃការអភិវឌ្ឍន៍សហគមន៍ដ៏ទូលំទូលាយនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការទស្សនៈពិភពលោកកម្ពុជា ។

បច្ចុប្បន្ននេះ វីសិនហ្វាន់កម្ពុជា មានវត្តមាននៅក្នុងស្រុកចំនួន ២៧ នៅខេត្តបាត់ដំបង កំពង់ធំ ព្រះវិហារ កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល តាកែវ ។ តាមរយៈធនាគារភូមិចំនួន ៧៦៣ វីសិនហ្វាន់កម្ពុជា កំពុងធ្វើឱ្យមានការផ្លាស់ប្តូរជីវិតរស់នៅរបស់សហគ្រិនក្រីក្រជាង ២០ 000 នាក់ ដោយក្នុងនោះ មានស្ត្រីជាង ១៦ 000 នាក់ ។

www.visionfund.org.nz






# កិច្ចការពារកុមារ

## ខែ មិថុនា ឆ្នាំ ២០០៤ :

"រំលោភកុមារនៅប្រទេសនេះ ត្រូវចូលពន្ធនាគារនៅប្រទេសរបស់អ្នក" ។ នេះជាការព្រមានយ៉ាងច្បាស់នៅក្នុងបដាយុទ្ធនាការថ្មីមួយ ដែលចាប់អនុវត្តក្នុងភាពជាដៃគូរវាងអង្គការទស្សនៈពិភពលោក និងក្រសួងការបរទេសសហរដ្ឋអាមេរិកផ្នែកអន្តោប្រវេសន៍ និងគយ ។

លោក ថាល់ម៉េជ្យ ផេន នាយកប្រចាំប្រទេសនៃអង្គការទស្សនៈពិភលោកកម្ពុជាបានថ្លែងថា :

*"យើងមានភាពម៉ឺងម៉ាត់ចំពោះកិច្ចការពារកុមារ ។ យើងចង់ឱ្យជនល្មើសដឹងច្បាស់ថា ប្រសិនបើគេរំលោភកុមារនៅកម្ពុជា ពួកគេនឹងត្រូវបានតាមដានចាប់ខ្លួន ហើយត្រូវចូលពន្ធធនាគារ" ។*

ក្នុងភាពជាដៃគូជាមួយ រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការបរទេសសហរដ្ឋអាមេរិក ស្ថានទូតចក្រភពអង់គ្លេស ស្ថានទូតអូស្ត្រាលី អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជនដទៃទៀត អង្គការទស្សនៈពិភលោកកម្ពុជា នឹងបន្តអនុវត្តគំរោងចំរុះជាច្រើនទៀត ដើម្បីលុបបំបាត់ការរំលោភកុមារដ៏ឃោរឃៅនៅកម្ពុជា ។

www.stopchildtourism.org

# កុមារកម្ពុជានាំមុខ

## ខែ កក្កដា ឆ្នាំ ២០០៤ :

មានអ្នកដឹកនាំជាកុមារចំនួន ១៧១ នាក់ បានជួបជុំគ្នាដើម្បីចូលរួមសិក្ខាសាលាថ្នាក់ដឹកនាំក្លឹបកុមាររបស់អង្គការទស្សនៈពិភពលោកកម្ពុជា ។ តំណាងឱ្យកុមារជាង ៧០០០ នាក់ ដែលបានចូលរួមក្នុងសកម្មភាពក្លឹបជាច្រើន សំរបសំរួលដោយអង្គការទស្សនៈពិភពលោកកម្ពុជា អ្នកដឹកនាំក្លឹបទាំងនេះរួមគ្នាចែករំលែកសមិទ្ធផល និងពិនិត្យមើលការលំបាកនៅតាមសហគមន៍របស់ខ្លួន ។ នៅអំឡុងពេលសិក្ខាសាលា កុមារទាំងនេះបានលើកជាអនុសាសន៍ចំពោះបញ្ហាផ្សេងៗ ដែលគេជួបប្រទះ និងសុំជំនួយគាំទ្រដែលគេត្រូវការពី អង្គការទស្សនៈពិភពលោកកម្ពុជា ដើម្បីបង្ការអំពើហិង្សា ក្នុងគ្រួសារ ការប្រើប្រាស់គ្រឿងញៀន ការជួញដូរមនុស្ស ការរំលោភកុមារ និងពលកម្មកុមារ ។

លោក ញឹម សម្បត្តិ ប្រធានគំរោងការពារកុមារដែលមានហានិភ័យខ្ពស់ នៃអង្គការទស្សនៈពិភលោកកម្ពុជាថ្លែងថា : *"តាមរយៈក្លឹបកុមារទាំងនេះ យើងសង្កេតឃើញថាកុមារត្រៀមខ្លួនជាស្រេច ដើម្បីធ្វើសកម្មភាពដោយភាពចាស់ទុំដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរ "* ។

កុមារ លីណាក់ អាយុ ១៥ ឆ្នាំ ជាអ្នកដឹកនាំក្លឹបកុមារនៅស្រុក កំពង់ត្រឡាច បានពោលថា : *"ជីវិតរបស់ខ្ញុំមានភាពប្រសើរជាងមុន ពីព្រោះឥឡូវនេះ ខ្ញុំបានយល់អំពីសិទ្ធិកុមារ និងរបៀបបង្ការការជួញដូរមនុស្ស ។ តាមរយៈក្លឹបកុមារ សហគមន៍របស់ខ្ញុំកំពុងតែរៀនសូត្រអំពីរបៀបកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ។ ទស្សនវិស័យរបស់ខ្ញុំ គឺចង់ក្លាយជាគ្រូបង្រៀន ដើម្បីអភិវឌ្ឍន៍កុមារ"* ។







# ការវាយតំលៃ

## ការងារអភិវឌ្ឍន៏សហគមន៏

### ខែ សីហា ឆ្នាំ ២០០៤ :

កម្មវិធីអភិវឌ្ឍន៏តំបន់ បាត់ដំបង បានធ្វើការវាយតំលៃប្រតិបត្តិការរបស់ខ្លួន ។ ការវាយតំលៃរបស់កម្មវិធីអភិវឌ្ឍន៏តំបន់របស់អង្គការទស្សនៈពិភពលោកកម្ពុជា ដើម្បីពិនិត្យមើលវឌ្ឍនភាពរបស់កម្មវិធីឆ្ពោះទៅកាន់គោលដៅ និងវត្ថុបំណងផ្អែកផលប៉ះពាល់ វាយតំលៃប្រសិទ្ធភាព ប្រសិទ្ធផល និងផលប៉ះពាល់នៃគំរោងផែនការបច្ចុប្បន្ន និងចង្អុលបង្ហាញពីចំណុចដែលត្រូវកែលំអនៅក្នុងផែនការយុទ្ធសាស្ត្រនៅពេលបន្ទាប់ ។

ការវាយតំលៃកម្មវិធីអភិវឌ្ឍន៏តំបន់ បាត់ដំបង បានទទួលស្គាល់សមិទ្ធផលជាច្រើនរបស់កម្មវិធីអភិវឌ្ឍន៏តំបន់ ។ មានស្ត្រីកាន់តែច្រើនឡើងកំពុងទទួលកិច្ចថែទាំសុខភាពនៅពេលមានផ្ទៃពោះជាងមុន ពីផ្អែកផ្តល់សេវាថែទាំសុខភាព ដែលគេទុកចិត្ត ។ ការចុះឈ្មោះចូលរៀន និងការនៅបន្តការសិក្សានៅក្នុងសាលាមានភាពប្រសើរឡើងនៅក្នុងតំបន់គោលដៅ ។ ប្រជាជនកាន់តែច្រើនមានកម្មសិទ្ធិដីធ្លីរស់នៅ និងមានសន្តិសុខស្បៀងច្រើនជាងកាលពី ៥ ឆ្នាំមុន ។

*www.transformational-development.org*

# ការស្រាវជ្រាវអំពីពិការភាព

## ខែ កញ្ញា  ឆ្នាំ ២០០៤ :

អង្គការទស្សនៈពិភពលោកកម្ពុជា និងក្រុមប្រឹក្សាសកម្មភាពជនពិការ បានចេញរបាយការណ៍ស្រាវជ្រាវដ៏ធំមួយ អំពីស្ថានភាពរបស់ជនពិការនៅកម្ពុជា ។ របាយការណ៍នេះ បង្ហាញអោយឃើញថា ជនពិការនៅកម្ពុជានៅជួបប្រទះឧបសគ្គធំៗជាច្រើន ដែលរារាំងពួកគេពីការចូលរួមយ៉ាងពេញលេញនៅក្នុងសង្គម ។

ការស្រាវជ្រាវនេះ ចង្អុលបង្ហាញថា ស្វ័យសំរេចចិត្ត ព្រមទាំងសមត្ថភាព និងសិទ្ធិចូលរួមយ៉ាងពេញលេញនៅក្នុងជីវភាពនៃសហគមន៍របស់ជនពិការនៅកម្ពុជា ត្រូវបានបដិសេធ ។ ការស្រាវជ្រាវនេះ ក៏បង្ហាញឱ្យឃើញផងដែរថា មានគ្រួសារជាច្រើនពុំមានធនធាន និងពតិមានដើម្បីថែទាំកុមារពិការឱ្យបានគ្រប់គ្រាន់ទេ ។ នេះជាមូលហេតុបង្កើនលទ្ធភាព វីភាពឯកកោ ជម្ងឺ និងការឆាប់ស្លាប់ ។

www.worldvision.org.kh/pdf/dr01-en.pdf



# របាយការណ៍

## ហិរញ្ញវត្ថុសង្ខេបសំរាប់អង្គការ ទស្សនៈពិភពលោកកម្ពុជា

ប្រាក់ចំនូលរបស់អង្គការទស្សនៈពិភពលោកកម្ពុជា ក្នុងឆ្នាំសារពើពន្ធ ២០០៤ (ខែ តុលា ឆ្នាំ ២០០៣ ដល់ ខែ កញ្ញា ឆ្នាំ ២០០៤) មានចំនួន ១៣.០៧៤.៦៨២ ដុល្លាអាមេរិក ។ ចំនួននេះរួមមាន ១.០៦៧.៤៨៩ ដុល្លាអាមេរិក ជាវិភាគទានដែលមិនមែនជាសាច់ប្រាក់ ដូចជា ជំនួយស្បៀងអាហារជាដើម ។ ចំនាយសរុបនៅឆ្នាំសារពើពន្ធ ២០០៤ គឺ ១២.៣៦៣.០២៨ ដុល្លាអាមេរិក ដែល ៨% ត្រូវបានចំនាយលើការគ្រប់គ្រងយុទ្ធសាស្ត្រ (ចំណាយផ្សេងៗ) ។




ការចំនាយរបស់អង្គការទស្សនៈពិភពលោកតាមផ្នែកនីមួយៗ

**យើងសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយនៅក្នុងឆ្នាំ ២០០៤ ទាំងអស់ ដូចខាងក្រោមនេះ :**

**ការិយាល័យផ្គត់ផ្គង់របស់អង្គការទស្សនៈពិភពលោក**

អូស្ត្រាលី កាណាដា អាល្លឺម៉ង់ ហុងកុង ជប៉ុន កូរ៉េ ម៉ាឡេស៊ី ហូឡង់ ណូវែសឺឡង់ សឹង្ហបុរី ស្វីស តៃវ៉ាន់ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ។

**ម្ចាស់ជំនួយ :**

ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ អូស្ត្រាលី (AusAID)
ស្ថានទូត អូស្ត្រាលី
កម្មវិធីសហប្រតិបត្តិការអង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលី (ANCP)
មូលនិធិសិក្សាស្រាវជ្រាវកសិកម្ម កម្ពុជា (CARF)
ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ កាណាដា (CIDA)
ស្ថានទូត ជប៉ុន
អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ (KHANA)
កម្មវិធីស្បៀងអាហារពិភពលោក (WFP)
ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
University Research Co., LLC (URC)
ក្រសួងការបរទេសសហរដ្ឋអាមេរិក
គំរោងគាំទ្រទីភ្នាក់ងារស្ម័គ្រចិត្ត (VASS)

# របាយការណ៍

## ហិរញ្ញវត្ថុសង្ខេបសំរាប់ វីសិនហ្វាន់កម្ពុជា

វីសិនហ្វាន់កម្ពុជា (VFC) គឺជាស្ថាប័នមីក្រូហិរញ្ញវត្ថុដាច់ដោយឡែកជាកម្មសិទ្ធិរបស់អង្គការទស្សនៈពិភពលោកកម្ពុជា ។ ឆ្នាំសារពើពន្ធរបស់ វីសិនហ្វាន់កម្ពុជា ស្របគ្នានឹងឆ្នាំប្រតិទិនដែរ ។ នៅ ដំណាច់ខែ ធ្នូ ឆ្នាំ ២០០៤ ដើមទុនរបស់ វីសិនហ្វាន់កម្ពុជា បានកើនឡើងដល់ ២.១៩៩.២៨៥ ដុល្លារអាមេរិក ហើយនៅខែ មករា ឆ្នាំ២០០៥ វីសិនហ្វាន់កម្ពុជា បានសំរេចនិរន្តរភាពផ្នែកប្រតិបត្តិការរបស់ខ្លួន ។




ផលប័ត្រ កម្មវិធីវិសិនហ្វាន់តាមខេត្តនីមួយៗ

ធនធានដែលយើងមានមិនមែនជាទ្រព្យសម្បត្តិរបស់យើងផ្ទាល់ទេ ។ ធនធានទាំងនេះជាសទ្ធាដ៏ពិសិដ្ឋរបស់ព្រះជាម្ចាស់ ដែលបានមកតាមរយៈម្ចាស់ជំនួយក្នុងនាមជនក្រីក្រ ។ អង្គការទស្សនៈពិភពលោកកម្ពុជា មានភាពស្មោះត្រង់នឹងគោលបំណង ដែលធនធានត្រូវប្រើប្រាស់ និងចាត់ចែងធនធានទាំងនោះ ក្នុងល័ក្ខខ័ណ្ឌមួយដែលផ្តល់អត្ថប្រយោជន៏អតិបរមាដល់ប្រជាជនក្រីក្រ ។ យើងនិយាយ និងប្រព្រឹត្តដោយស្មោះត្រង់ ។ យើងបើកចំហរ និងឈរលើការពិតក្នុងការទំនាក់ទំនងជាមួយមជ្ឈដ្ឋានម្ចាស់ជំនួយសហគមន៏គំរោង រដ្ឋាភិបាល សាធារណជនជាទូទៅ និងរវាងគ្នាទៅវិញទៅមក ។ យើងទាមទារអោយខ្លួនយើងផ្ទាល់មានសមត្ថភាពវិជ្ជាជីវៈក្នុងកំរិតខ្ពស់ ហើយទទួលយកតំរូវការអោយមានការទទួលខុសត្រូវតាមរយៈរចនាសម្ព័ន្ធត្រឹមត្រូវ ដើម្បីទទួលបាននិយាមទាំងនេះ ។

# តំលៃជាមូលដ្ឋាន៖

## ១ យើងជាគ្រីស្ទបរិស័ទ

យើងបានទទួលការត្រាស់ហៅឱ្យបំរើអ្នកដទៃក្នុងភាពបរិបូរណ៌នៃសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ ។

## ២ យើងប្តេជ្ញាជួយដល់ជនក្រីក្រ

យើងត្រូវត្រាស់ហៅអោយសំរាលតំរូវការ និងទុក្ខវេទនា ភ្ជាប់ទំនាក់ទំនង រវាងអ្នកក្រ និងអ្នកមាន ។

## ៣ យើងគោរពតំលៃមនុស្ស

យើងចាត់ទុកមនុស្សទាំងអស់ថា ត្រូវបានបង្កើត និងស្រលាញ់ដោយព្រះជាម្ចាស់ដោយម្នាក់ៗ មានលក្ខណៈពិសេស ទទួលសេចក្តីថ្លៃថ្នូរ ការគោរព និងមានតំលៃក្នុងខ្លួន ។

## ៤ យើងជាអ្នកបំរើដែលមានការទទួលខុសត្រូវខ្ពស់

យើងស្មោះត្រង់ចំពោះគោលបំណងនៃធនធានដែលយើងបានទទួល និងគ្រប់គ្រងធនធានទាំងនោះ ក្នុងរបៀបមួយដែលនាំមកនូវផលប្រយោជន៍ជាអតិបរមាដល់ជនក្រីក្រ ។

## ៥ យើងជាដៃគូ

ក្នុងនាមជាសមាជិកនៃអង្គការទស្សនៈពិភពលោកអន្តរជាតិ យើងព្រមទទួលយកកាតព្វកិច្ច ដែលមានការចូលរួមគោលដៅរួម និងមានគណនេយ្យភាពទៅវិញទៅមក ។

## ៦ យើងជាអ្នកឆ្លើយតប

យើងឆ្លើយតបចំពោះគ្រោះអាសន្នដែលគំរាមកំហែងដល់អាយុជីវិត ព្រមទាំងស្ថានភាពសេដ្ឋកិច្ចសង្គមស្មុគស្មាញដែលតំរូវអោយមានការអភិវឌ្ឍន៍យូរអង្វែង ។



# អង្គការទស្សនៈពិភពលោកកម្ពុជា

## ទស្សនៈវិស័យ

ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ជាពិសេសកុមាររស់នៅប្រកបដោយជីវិតពេញបរិបូរណ៌ សន្តិភាព និងយុត្តិធម៌ ។

## សេចក្តីថ្លែងការណ៍បេសកកម្ម

ជាក្រុមការងារមួយដែលមានព្រះគ្រីស្ទជាគោលប្តេជ្ញាចិត្តធ្វើការជាមួយសហគមន៍ក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់លើកុមារ ដើម្បីផ្លាស់ប្រែជីវិតនិងសង្គមកម្ពុជាតាមរយៈការអភិវឌ្ឍន៍ដែលមាននិរន្តរភាព ។

បោះពុម្ពផ្សាយនៅកម្ពុជា ឆ្នាំ ២០០៥

**សរសេរដោយ៖**
រេបេកា មួស

**រូបថតដោយ៖**
ខែម សុវណ្ណារ៉ា
សុខ ណាលី
វុធ លីណូ

**រចនាក្រាហ្វិច និងកាច់ទំព័រដោយ៖**
ក្រាហ្វិចរូត
graphicroots@online.com.kh

ផ្នែកនៃពត៌មាននេះអាចនឹងបោះពុម្ពផ្សាយបន្ត ប្រសិនបើមានការអនុញ្ញាត ។

**របាយការណ៍នេះអាចរកបានពី៖**

**អង្គការទស្សនៈពិភពលោកកម្ពុជា**

ផ្ទះលេខ ២០ ផ្លូវលេខ ៧១ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ កម្ពុជា
ទូរស័ព្ទ : +៨៥៥-២៣-២១៦០៥២
ទូរសារ : +៨៥៥-២៣-២១៦២២០
អ៊ីម៉ែល : Cambodia@wvi.org
គេហទំព័រ: www.worldvision.org.kh

World Vision


អង្គការទស្សនៈពិភពលោកកម្ពុជា

ប្រអប់សំបុត្រលេខ ៤៧៩ ភ្នំពេញ កម្ពុជា

Cambodia@wvi.org - www.worldvision.org.kh